# ស្វែងយល់

## អំពី ចំណេះដឹង ៥ ប្រការ

០១ ការធ្វើអនាម័យជាមូលដ្ឋាន

០២ សុខភាពរបស់ស្ត្រី

០៣ ការពន្យារកំណើត

០៤ ការថែទាំអំឡុងពេលមានផ្ទៃពោះ

០៥ មហារីកមាត់ស្បូន

# ០១ ការធ្វើអនាម័យជាមូលដ្ឋាន

អនាម័យ គឺជាការអនុវត្តន៍ទាំងឡាយណាដែលធ្វើឱ្យមនុស្សយើង ឬអ្វីៗដែលនៅជុំវិញយើង មានភាពស្អាតក្នុងគោលបំណងបង្ការជំងឺ ឬបង្ការការឆ្លងរាលដាលនូវជំងឺផ្សេងៗ។ អនាម័យមានដូចជាអនាម័យ ចំណីអាហារ ទឹក ខ្លួនប្រាណ សម្លៀកបំពាក់ លំនៅឋាន កន្លែងធ្វើការ និងទីសាធារណៈ។



១- សម្អាតផ្ទះរបស់អ្នកឱ្យបានទៀងទាត់ និងការរក្សាថែបន្ទប់របស់អ្នក ឱ្យមានខ្យល់ចេញចូល និងពន្លឺគ្រប់គ្រាន់។

២- គ្របអាហារដើម្បីចៀសវាងពីសត្វល្អិត និងផឹកទឹកស្អាត។

៣- មិនគួរចែករំលែកឡាមកោរ និងកន្សែងជាមួយអ្នកផ្សេងទៀត។ ប្រសិនបើអ្នកបានធ្វើការចែករំលែកកន្សែង ឬសម្លៀកបំពាក់ជាមួយ អ្នកដទៃ អ្នកត្រូវប្រាកដថា របស់នោះបានសម្អាតរួចរាល់ហើយ មុននិងក្រោយពេលប្រើរួច។



៤- ដុសធ្មេញអាចជួយការពារកុំឱ្យធ្មេញប្រហោង និង ជំងឺអញ្ចាញធ្មេញ ដែលត្រូវបានផ្សារភ្ជាប់ទៅនឹងជំងឺផ្សេងទៀតនៅក្នុងរាងកាយ។

# លាងសម្អាតដៃរបស់អ្នកជាមួយនឹងសាប៊ូជានិច្ច



នេះជាវិធីដ៏សំខាន់បំផុតដើម្បីឱ្យអ្នកជៀសវាង ពីការឈឺ៖

- មុនពេលហូបចំណីអាហារ៖ ត្រូវតែលាងដៃឱ្យបានស្អាតជាមួយសាប៊ូ ព្រោះដៃយើងអាចមានប្រឡាក់មេរោគគ្រប់យ៉ាង។
- ពេលចេញពីបង្គន់ និងបន្ទាប់ពីប៉ះពាល់វត្ថុមិនស្អាត៖ ដាច់ខាត ត្រូវតែលាងដៃរបស់អ្នក ជាមួយសាប៊ូឱ្យបានស្អាត។

## លាងសម្អាតដៃរបស់អ្នក



០២

# សុខភាពរបស់ស្ត្រី

## វដ្តជីវិតរបស់ស្ត្រី




## វដ្តនៃការមានឈាមរដូវ និងការធ្លាក់ស

ការមានឈាមរដូវគឺជាការរបេះធ្លាក់នៃស្រទាប់ភ្នាសស្តើងខាងក្នុងតួស្បូន ហើយហូរចេញមកក្រៅតាមទ្វារមាសជារៀងរាល់ខែ ចំពោះស្ត្រីដែលឋិតក្នុងវ័យបន្តពូជ។ ជាទូទៅឈាមរដូវមកទៀងទាត់រាល់ខែ ត្រូវបានគេហៅថាវដ្តរដូវ។ តាមរយៈវដ្តរដូវនេះស្ត្រីអាចរៀបចំខ្លួនដើម្បីមានកូន។ ជាធម្មតា ស្ត្រីមានវដ្តឈាមរដូវរាល់២៨ថ្ងៃម្តង។ វដ្តឈាមរដូវរបស់ស្ត្រីម្នាក់ៗ មិនដូចគ្នាទេ ស្ត្រីអាចមានវដ្តឈាមរដូវចន្លោះពី ២១ថ្ងៃ ទៅ ៣៥ថ្ងៃ។ ជាមធ្យម ស្ត្រីអាចធ្លាក់ឈាមរដូវ រយៈពេលពី ២ទៅ៧ថ្ងៃ។ ប្រសិនបើវដ្តរដូវរបស់អ្នក មាន២៨ថ្ងៃ ថ្ងៃធ្លាក់មេជីវិតញី (ពងអូវុល) គឺនៅពាក់កណ្តាលនៃវដ្តរដូវ ដែលមានន័យប្រហែលថ្ងៃទី១៤មុនពេលមានរដូវបន្ទាប់។



ជាទូទៅ បរិមាណនៃការធ្លាក់ស បានកើនឡើងនៅជុំវិញថ្ងៃធ្លាក់មេជីវិតញី។ អ្នកអាចធ្លាក់រំអិលដែលមានសភាពអន្លាយថ្លាៗ។

# ការធ្លាក់សខុសធម្មតា

- មានការប្រែពណ៌លឿង បៃតង មានក្លិន  និង មានការរមាស់
- មានបរិមាណច្រើនជាងធម្មតា
- ជួនមានការឈឺចាប់



បើសិនជាអ្នកមានការធ្លាក់សខុសពីធម្មតា សូមទៅពិគ្រោះជាមួយគ្រូពេទ្យ។

## រដូវឈាមរដូវ ២៨ថ្ងៃម្តង









# ការថែទាំខ្លួនពេលមានឈាមរដូវ





## ការប្រព្រឹត្តប្រចាំថ្ងៃដែលនាំឱ្យអ្នកមានសុខភាព

ការយល់ដឹងអំពីល័ក្ខខ័ណ្ឌនៃវដ្តឈាមរដូវ

- កត់ត្រាថ្ងៃមានឈាមរដូវ លើប្រតិទិន
- ពិនិត្យមើលសភាពរបស់ស ដែលធ្លាក់ចេញតាមទ្វារមាស

ការអនាម័យខ្លួនប្រាណ និងប្រដាប់ភេទ

- ស្ត្រីត្រូវងូតទឹកសំអាតខ្លួនប្រាណ និងដុសលាងប្រដាប់ភេទជាមួយទឹក ឱ្យបានស្អាត យ៉ាងហោចណាស់ឱ្យបាន២ដងក្នុង១ថ្ងៃ។ ពេលងូតទឹកសម្អាតខ្លួនមិនចាំបាច់ដុសសាប៊ូនៅម្តុំប្រដាប់ភេទទេ ព្រោះផ្នែកខាងក្នុងនៃរន្ធទ្វារមាស មានកំហាប់សារធាតុម្យ៉ាងពីធម្មជាតិ ដែលអាចការពារមិនឱ្យបាក់តេរីជ្រៀតចូលទៅបង្ករោគបាន។
- ស្លៀកខោក្នុងដែលបានបោកគក់ស្អាត និងងាយស្រួល  សម្រាប់ទ្រាប់សំឡី អនាម័យផងដែរ។
- ផ្លាស់ប្តូរសំឡីអនាម័យឱ្យបាន ៣-៤ដង ក្នុង១ថ្ងៃ។



មិនត្រូវទ្រាំដល់ឈឺនោមខ្លាំងនោះទេ  អ្នកគួរតែប្រញាប់ប្រញាល់ទៅបន្ទប់ទឹក។

០៣

# ការពន្យារកំណើត

## មានកូនតាមប្រាថ្នាប្រសើរជាងមានកូនដោយចៃដន្យ



## សារៈប្រយោជន៍នៃការពន្យារកំណើត

1- ធ្វើឱ្យសុខភាពម្ដាយ នឹងមានពេលពង្រឹងកំលាំងឡើងវិញ បន្ទាប់ពីសម្រាល

2- កូនមានសុខភាពល្អ ព្រោះកូនអាចបៅដោះម្ដាយបានយូរ

3- ឪពុកម្ដាយមានពេលគ្រប់គ្រាន់សម្រាប់ថែទាំកូនឱ្យបានល្អ

4- បន្ថយគ្រោះថ្នាក់ក្នុងពេលស្ត្រីមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាល

5- បន្ថយគ្រោះថ្នាក់ពីការមានផ្ទៃពោះដែលមិនចង់បាន និងជៀសវាងការរំលូតកូនដែលមិនមានសុវត្ថិភាព។



- ប្រសិនបើអ្នកចង់ប្រើមធ្យោបាយពន្យារកំណើតទំនើបណាមួយសម្រាប់ការពន្យារកំណើតសូមទៅជួបអ្នកផ្ដល់សេវាដែលមានជំនាញនៅឯមណ្ឌលសុខភាពជិតផ្ទះអ្នក។
- សម្រាប់ការបញ្ឈប់កំណើតអចិន្ត្រៃយ៍ មាននៅតាមមន្ទីរពេទ្យ។

# មធ្យោបាយពន្យារកំណើត



ថ្នាំគ្រាប់

- ថ្នាំ១បន្ទះ អាចការពារមិនឱ្យមានផ្ទៃពោះបាន១ខែ
- មុនលេបត្រូវពិគ្រោះយោបល់ ជាមួយអ្នកផ្តល់សេវា នៅមណ្ឌលសុខភាព ឬ នៅមន្ទីរពេទ្យ
- ត្រូវលេបថ្នាំ ១ថ្ងៃ១គ្រាប់ តាមសញ្ញាព្រួញ រៀងរាល់ថ្ងៃ ក្នុងម៉ោងដដែល
- ស្ត្រីមានរដូវទៀងទាត់ បន្ថយភាពស្លេកស្លាំង
- ស្ត្រីនឹងមានកូនវិញ ក្រោយពីឈប់លេបថ្នាំ



ថ្នាំចាក់

- ថ្នាំពន្យារកំណើត១ម្ជុល ការពារមិនឱ្យមានផ្ទៃពោះ បាន៣ខែ
- មានប្រសិទ្ធិភាពខ្ពស់ មិនរំខានដល់ការរួមភេទ
- សមស្របចំពោះស្ត្រី កំពុងបំបៅដោះកូន
- ស្ត្រីអាចបាត់រដូវមួយរយៈក្រោយពីចាក់ថ្នាំ តែមិនប៉ះពាល់ដល់សុខភាពទេ



ស្រោមអនាម័យ

- ស្រោមអនាម័យមួយ អាចប្រើបានតែម្តងគត់
- មុនប្រើត្រូវពិនិត្យថ្ងៃខែផុតកំណត់ នៅលើសំបកស្រោម
- ត្រូវច្របាច់ចុងស្រោម រួចពាក់លើលិង្គដែលកំពុងរឹង
- ប្រើស្រោមអនាម័យមិនធ្វើឱ្យស្ត្រីរលាកស្បូនទេ
- ការពារការមានផ្ទៃពោះ ជំងឺកាមរោគ និងជំងឺអេដស៍



ថ្នាំគ្រាប់ការពារកំណើតបន្ទាន់

- ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ គឺជាថ្នាំគ្រាប់ដែលគេ ប្រើភ្លាមៗ ក្នុងអំឡុងពេល៧២ម៉ោង បន្ទាប់ពីមាន ការរួមភេទដែលមិនបានការពារ

# មធ្យោបាយពន្យារកំណើតរយៈពេលយូរនិងអចិន្ត្រៃយ៍





កងដាក់ក្នុងស្បូន(TCu 380A)

- មានប្រសិទ្ធិភាពខ្ពស់ អាចការពារការមានផ្ទៃពោះបានរហូតដល់១០ឆ្នាំ
- មិនរំខានដល់ការរួមភេទ
- មិនរំខានដល់ការងារប្រចាំថ្ងៃរបស់ស្ត្រី
- អាចការពារជំងឺមហារីកស្រទាប់ក្នុងនៃស្បូន
- អាចមានឈាមរដូវច្រើនជាងមុន (បរិមាណច្រើន និងរយៈពេលវែង)



កងដាក់ក្រោមស្បែក

- ចាឌែល (Jadelle) មានចំនួន២ដើម មានការពារមិនឱ្យមានកូនរយៈពេល៥ឆ្នាំ
- អ៊ីមផ្លាណុន (Implanon) មាន១ដើម មានប្រសិទ្ធិភាពរយៈពេល៣ឆ្នាំ
- ស្ត្រីអាចធ្វើការងារដូចធម្មតា
- ស្ត្រីអាចមានរដូវមិនទៀងទាត់ ឬអាចបាត់ឈាមរដូវមួយរយៈ



ចងដៃស្បូន

- ជាវិធីសម្រាប់ស្ត្រីដែលលែងចង់បានកូនតទៅទៀត
- ស្ត្រីអាចធ្វើការងារដូចធម្មតា
- ស្ត្រីនៅតែមានរដូវរាល់ខែ ហើយមានអារម្មណ៍រួមភេទធម្មតា
- មិនអាចការពារការឆ្លងរោគតាមផ្លូវបន្តពូជ



ចងបំពង់បង្ហូរមេជីវិតឈ្មោល

- មិនប៉ះពាល់ដល់សុខភាពបុរសទេ ហើយអាចរួមភេទ និងមានទឹកកាមធម្មតា តែភរិយារបស់អ្នកគ្មានផ្ទៃពោះទេ
- មិនអាចការពារការឆ្លងរោគតាមផ្លូវបន្តពូជ

០៤

# ការថែទាំអំឡុងពេលមានផ្ទៃពោះ

## ជាធម្មតាការមានផ្ទៃពោះគឺមានរយៈពេលប្រមាណ៤០សប្តាហ៍



## សញ្ញាដំបូងនៃការមានផ្ទៃពោះ

1- ការបាត់រដូវ
2- ការក្អួតចង្អោរពេលព្រឹក
3- សុដន់រីកធំ និងមានអារម្មណ៍ថាតឹងណែន
4- នោមញឹកញាប់ជាងធម្មតា
5- ចំណង់ចំណូលចិត្តចម្លែក ដូចជាឃ្លានប្លែក ឬធុំក្លិនចង់ក្អួត



នៅពេលមានសញ្ញាបែបនេះ គួរតែទៅពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ដើម្បីឱ្យដឹងច្បាស់ថាមានផ្ទៃពោះពិតឬទេ ហើយនឹងទទួលបានការណែនាំស្តីពីរបៀបថែទាំផ្ទៃពោះ។

# ការថែទាំពេលមានផ្ទៃពោះ

ការថែទាំពេលមានផ្ទៃពោះ គឺជាការថែទាំសុខភាព និងផ្តល់ការអប់រំនៅពេលស្ត្រី មកពិនិត្យផ្ទៃពោះទៀងទាត់ជាមួយឆ្មប ឬវេជ្ជបណ្ឌិត យ៉ាងហោចណាស់ឱ្យបាន៤ដង ក្នុងអំឡុងពេលមានផ្ទៃពោះ

- លើកទី១ នៅត្រីមាសទី១ (អាចមុន ១៦សប្តាហ៍)
- លើកទី២ នៅត្រីមាសទី២ (គួរនៅចន្លោះ ២៤-២៨សប្តាហ៍)
- លើកទី៣ នៅត្រីមាសទី៣ (គួរនៅចន្លោះ ៣០-៣២សប្តាហ៍)
- លើកទី៤ ធ្វើនៅពេលគភ៌គ្រប់ខែ (គួរនៅចន្លោះ ៣៦-៣៨សប្តាហ៍)




៤០សប្តាហ៍នៃការមានផ្ទៃពោះ

## អត្ថប្រយោជន៍នៃការពិនិត្យផ្ទៃពោះ

1- ដឹងពីសុខភាពរបស់ម្តាយ និងការវិវត្តន៍របស់ទារកក្នុងផ្ទៃ

2- ដឹងពីសញ្ញាគ្រោះថ្នាក់ផ្សេងៗដែលកើតមានចំពោះស្ត្រី និងទារក

3- ទទួលបានការចាក់ថ្នាំការពារជំងឺតេតាណូសតាមពេលកំណត់ និងថ្នាំគ្រាប់ជាតិដែកអាស៊ីតហ្វូរីក

4- ទទួលការព្យាបាលឬការណែនាំទាន់ពេលវេលា

5- ទទួលបាននូវការអប់រំថែទាំសុខភាព និងការបរិភោគចំណីអាហារក្នុងអំឡុងពេល មានផ្ទៃពោះ

# ចំណុចដែលស្ត្រីគួរនិងមិនគួរធ្វើពេលមានផ្ទៃពោះ



## ចំណុចដែលស្ត្រីគួរធ្វើពេលមានផ្ទៃពោះ

+ ទទួលទានវីតាមីន និងអាហារ ផ្លែឈើ ល្អៗ
+ ណាត់ជួបគ្រូពេទ្យ ឬអ្នកជំនាញដើម្បីពិនិត្យពោះ
+ ប្រឹក្សាជាមួយគ្រូពេទ្យ ឬអ្នកជំនាញមុនប្រើប្រាស់ឱសថ
+ តាមដានការវិវត្តន៍របស់កូនក្នុងផ្ទៃ
+ ធ្វើគម្រោងការចំណាយសម្រាប់កូន
+ ពិចារណារកកន្លែងណាដែលត្រូវសម្រាល





## ចំណុចដែលស្ត្រីមិនគួរធ្វើពេលមានផ្ទៃពោះ

- ការនៅជិត ឬប៉ះពាល់ថ្នាំសំលាប់សត្វល្អិត
- ការជក់បារី ឬផឹកគ្រឿងស្រវឹង ឬនៅជិតអ្នកកំពុងជក់បារី
- ការធ្វើដំណើរផ្លូវឆ្ងាយរលាក់
- ការប្រើប្រាស់ថ្នាំដោយគ្មានការអនុញ្ញាតិពីគ្រូពេទ្យ
- រួមភេទញឹកញាប់ (ពិសេសត្រីមាសទី១ និងទី៣)

# ០៤ មហារីកមាត់ស្បូន



នាំគ្នាទៅធ្វើតេស្តស្រាវជ្រាវរកមហារីកមាត់ស្បូនដើម្បីសុខភាពរបស់យើង

- តើអ្នកធ្លាប់បានឮ ថាមានអ្នកស្លាប់ដោយសារជំងឺរបស់ស្ត្រី ឬមហារីកមាត់ស្បូននេះ ដែរឬទេ?
- មហារីកមាត់ស្បូនជាជំងឺសម្បូរជួបមួយក្នុងចំណោមជំងឺមហារីកផ្សេងៗទៀតរបស់ស្ត្រី។
- ស្ត្រីដែលមានមហារីកមាត់ស្បូនអាចមានរោគសញ្ញាណាមួយដូចខាងក្រោម៖
    - ធ្លាក់សខុសធម្មតា
    - ធ្លាក់ឈាមនៅចន្លោះវដ្តឈាមរដូវ
    - ធ្លាក់ឈាមក្រោយវ័យអស់រដូវ
    - មានធ្លាក់ឈាម ឬឈឺពេលរួមភេទ
- នៅប្រទេសកម្ពុជា ជារៀងរាល់ឆ្នាំ មានស្ត្រីជាច្រើននាក់បានស្លាប់ដោយសារមហារីកមាត់ស្បូន។
- ប៉ុន្តែបើស្ត្រីទាំងនោះបានយល់ដឹងអំពីរបៀបការពារពីជំងឺនេះ ពួកគាត់នឹងមិនស្លាប់ដោយសារមហារីកមាត់ស្បូននេះទេ។

# មហារីកមាត់ស្បូនបណ្តាលមកពីវីរុសឈ្មោះអេច ភី វី (HPV)



វីរុសអេច ភី វី បង្កគ្រោះថ្នាក់ខ្ពស់
មាន១៣ប្រភេទ ពិសេស
ប្រភេទ១៦ និងប្រភេទ១៨

## មហារីកមាត់ស្បូន



ទិដ្ឋភាព
ខាងមុខ



ទិដ្ឋភាព
មាត់ស្បូន
ក្នុងទ្វារមាស



# តើស្ត្រីឆ្លងវីរុសអេច ភី វី (HPV) បង្កជាមហារីកមាត់ស្បូនយ៉ាងដូចម្តេច?

- ស្ត្រីឆ្លងវីរុសអេច ភី វី (HPV) ប្រភេទដែលអាចបណ្តាលឱ្យកើតជាមហារីកមាត់ស្បូនបានតាមរយៈការរួមភេទ *
- ការឆ្លងវីរុសអេច ភី វី (HPV) ត្រូវបានគេចាត់ទុកដូចជាជំងឺកាមរោគដែរ **
- ភាគច្រើននៃស្ត្រីដែលធ្លាប់មានទំនាក់ទំនងផ្លូវភេទ អាចប្រឈមនឹងការឆ្លងវីរុសអេច ភី វី (HPV) បាននៅក្នុងដំណាក់កាលណាមួយនៃជីវិតរបស់ពួកគេ។



កំណត់សម្គាល់:

* ការរួមភេទរាប់បញ្ចូលទាំងការប៉ះពាល់ស្បែកនៅតំបន់ប្រដាប់ភេទ (ប្រុសឬស្រី) មិនមែនគ្រាន់តែជាការរួមភទដោយប្រើប្រដាប់ភេទនោះទេ។

* * វីរុសអេច ភី វី (HPV) មិនឆ្លងតាមបង្គន់ កន្លែងអង្គុយ ឬចាប់ដៃគ្នាឡើយ។



# តើមានអ្វីកើតឡើងប្រសិនបើវីរុសអេច ភី វី (HPV) ដែលបង្គគ្រោះថ្នាក់ខ្ពស់ ស្ថិតនៅក្នុងមាត់ស្បូនរបស់អ្នក?




- ក្នុងចំណោមស្ត្រី១០០០០នាក់ មានស្ត្រី៦០០០នាក់ បានឆ្លងវីរុសអេច ភី វី (HPV)។ ហើយ១ក្នុងចំណោមស្ត្រី១០០នាក់ ដែលមានផ្ទុក វីរុសអេច ភី វី (HPV) អាចឈានដល់មាត់ស្បូនត្រៀមមហារីក ហើយមាន១ក្នុងចំណោមស្ត្រី១០នាក់ ដែលមានមាត់ស្បូនត្រៀមមហារីកក្លាយទៅជាមហារីក។
- រាប់ចាប់តាំងពីពេលដែលមានវីរុសអេច ភី វី (HPV) មកស្ថិតនៅក្នុងមាត់ស្បូនរហូតដល់ពេលក្លាយជាមហារីក មានរយៈពេលប្រហែល១០ឆ្នាំ។
- ដូចនេះមិនមានអ្នកណាម្នាក់ដឹងខ្លួនជាមុនថានឹងកើតមានមហារីកនោះទេ។ នេះជាហេតុផលមួយដែលស្ត្រីត្រូវតែទៅធ្វើតេស្តដើម្បីស្រាវជ្រាវរកមហារីកមាត់ស្បូនឱ្យបានឆាប់ និងទាន់ពេលវេលា។

## តើត្រូវធ្វើដូចម្តេចដើម្បីជៀសវាងពីមហារីកមាត់ស្បូន?

- ការប្រើស្រោមអនាម័យ
- មានដៃគូរួមភេទតែមួយ
- ការឆាប់ចាក់ថ្នាំបង្ការ ៖
  ការផ្តល់ថ្នាំបង្ការនឹងមានប្រសិទ្ធភាពខ្ពស់ ប្រសិនបើ គេផ្តល់ឱ្យស្ត្រីតាំងពីនៅវ័យក្មេង មុនពេលមានការរួមភេទ។
- ធ្វើតេស្តស្រាវជ្រាវរកមហារីកមាត់ស្បូន ឱ្យបានទៀងទាត់តាមការណាត់ជួប ដើម្បីឆាប់រកឃើញនូវភាពប្រែប្រួលនៃមាត់ស្បូន និងព្យាបាលឱ្យបានទាន់ពេល។



## សារគន្លឹះ

- គ្រប់ស្ត្រីដែលធ្លាប់មានការរួមភេទ អាចប្រឈមនឹងមហារីកមាត់ស្បូន។
- ដំបូងមហារីកមាត់ស្បូនសំងំយ៉ាងស្ងៀមស្ងាត់ មុននឹងដល់ពេលរាលដាល។ ដូចនេះមិនមានអ្នកណាម្នាក់ដឹងខ្លួនជាមុនថា នឹងមានមហារីកមាត់ស្បូនទេ។
- គ្រប់ស្ត្រីដែលធ្លាប់មានការរួមភេទដំបូងលើសពី ២ឆ្នាំ ពិសេសមានអាយុចាប់ពី២៥ឆ្នាំឡើង គប្បីទៅធ្វើតេស្តស្រាវជ្រាវរកមហារីកមាត់ស្បូន ឱ្យបានទៀងទាត់រៀងរាល់ពីរឆ្នាំម្តង។

ក្រសួងសុខាភិបាល
Ministry of Health

SCGO: Cambodian Society of Gynecology and Obstetrics

JSOG: Japan Society of Obstetrics and Gynecology

NCGM: National Center for Global Health and Medicine

JICA: Japan International Cooperation Agency

**SCGO**

Website: http://scgo-kh.com

ផលិតដោយ SCGO
ឧបត្ថម្ភដោយ JSOG, NCGM, and JICA

បោះពុម្ពលើកទី១
ចំនួន១០០០០ក្បាល ឆ្នាំ២០១៨
© រក្សាសិទ្ធិគ្រប់យ៉ាង